

# ការគំរាមឬការជំរិតផ្លូវភេទ

## និយមន័យ

### ការគំរាមឬការជំរិតផ្លូវភេទ

ការគំរាមឬការជំរិតផ្លូវភេទ ជាដំណើរការដែលបុគ្គលម្នាក់ត្រូវបានគេបង្ខិតបង្ខំឱ្យបំពេញចំណង់ផ្លូវភេទ ទាប្រាក់និងរបស់របរផ្សេងៗ ឬឲ្យផលិតរូបភាព ឬសម្ភារៈពាក់ព័ន្ធនឹងផ្លូវភេទផ្សេងទៀត។

ការគំរាម ឬការជំរិតផ្លូវភេទ ត្រូវបានកំណត់ដោយការប្រើប្រាស់អំណាចដែលគ្មានតុល្យភាពរវាងជនល្មើស និងជនរងគ្រោះ ដែលធ្វើឲ្យជនល្មើសអាចបង្ខិតបង្ខំជនរងគ្រោះឲ្យព្រមធ្វើតាមតម្រូវការផ្លូវភេទ ឬតម្រូវការហិរញ្ញវត្ថុ។




### គោលការណ៍ច្បាប់

ការគំរាម ឬការជំរិតផ្លូវភេទ មិនត្រូវបានចាត់ទុកយ៉ាងទូលំទូលាយថាជាបទល្មើសព្រហ្មទណ្ឌក្នុងលិខិតតុបករណ៍ក្នុងតំបន់ ឬអន្តរជាតិ ត្រង់ចំណុចការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនោះទេ ។

ប៉ុន្តែទោះជាយ៉ាងណាក្តី <u>អនុសញ្ញាទីក្រុងឡានហ្សារ៉ូត</u> បានចាត់សកម្មភាពដែលបណ្តាលឲ្យ ឬបង្ខំកុមារចូលរួមក្នុងសកម្មភាពពាក់ព័ន្ធនឹងរូបភាព និងសម្ភារៈអាសអាភាស ថាជាបទល្មើសព្រហ្មទណ្ឌ មាត្រា (Art. 21(1)(a-b))។ ស្រដៀងគ្នានេះដែរ សកម្មភាពនៃការលួងលោមសម្របសម្រួលកុមារដើម្បីឲ្យផលិតរូបភាព ឬសម្ភារៈអាសអាភាសកុមារនោះ ក៏ត្រូវបានចាត់ជាបទល្មើសផងដែរ (Art. 23)។ សកម្មភាពដែលទាក់ទងនឹងផ្លូវភេទជាមួយកុមារត្រូវបានចាត់ជាបទល្មើសព្រហ្មទណ្ឌ នៅពេលដែល ការបង្ខិតបង្ខំ ឬការគំរាមកំហែងកើតមានឡើង នៅពេលដែលជនល្មើសនោះរំលោភសេចក្តីទុកចិត្ត អំណាច ឬឥទ្ធិពលលើកុមារ ឬនៅពេលដែលកុមារស្ថិតក្រោមស្ថានភាពងាយរងគ្រោះ។

មាត្រាទាំងនេះ អាចត្រូវបានគេបកស្រាយដោយគ្របដណ្តប់ធាតុផ្សំនៃការជំរិត ឬគំរាមផ្លូវភេទ។

បន្ថែមលើនេះ អនុសញ្ញានានាដែលចាត់ការផលិត ការផ្តល់ឲ្យ ការចែកចាយ ឬការផ្តល់ឲ្យនូវរូបភាព ឬសម្ភារៈអាសអាភាសកុមារ ថាជាបទល្មើសព្រហ្មទណ្ឌ ឧទាហរណ៍<u>អនុសញ្ញាទីក្រុងប៊ុយតាប៉ែស អនុសញ្ញាទីក្រុងឡានហ្សារ៉ូត ពិធីសារដែលជាត្រង់ចំនុច ការជួញដូរកុមារ អនុសញ្ញាស្តីពីបទល្មើសកុំព្យូទ័ររស់ហាគមន៍ អាហ្វ្រិក</u>- ដែលចែងអំពីចំណុចដែលអាចគ្របដណ្តប់ធាតុផ្សំនៃការជំរិត ឬគំរាមខាងផ្លូវភេទ។

## អ្នកប្រព្រឹត្តបទល្មើស និងលក្ខណៈពិសេសនៃការគំរាមឬការជំរិតផ្លូវភេទ

- ជាញឹកញាប់ជនល្មើស ពឹងផ្អែកលើអំណាចតួនាទី ឬ **ប្រើអំណាចដែលគ្មានតុល្យភាព** ជាជាងការប្រើអំពើហិង្សាលើរាងកាយ ឬបង្ខិតបង្ខំឲ្យកុមារបំពេញចំណង់ផ្លូវភេទ ឬទាប្រាក់កាស ឬរបស់របរផ្សេងៗ
- ជាទូទៅការបង្ខិតបង្ខំផ្លូវចិត្ត បង្ហាញឲ្យឃើញដោយ**ការគំរាមកំហែងពីការដកចេញនូវផលប្រយោជន៍ជាក់លាក់ផ្សេងៗ ឬគំរាមកំហែងពីផលវិបាកដែលកុមារមិនចង់ជួបប្រទះ**បើការទាមទារនានារបស់ជនល្មើសមិនត្រូវបានបំពេញនោះទេ
- ធាតុផ្សំនៃការកេងប្រវ័ញ្ចផ្លូវភេទអាចពាក់ព័ន្ធនឹង**ការទាមទាររបស់ជនល្មើស** ដើម្បីទទួលបាននូវសកម្មភាពផ្លូវភេទដែលកុមារមិនចង់ធ្វើ ដូចជាការបង្ហាញឱ្យឃើញផ្នែកឯកជននៃរាងកាយរបស់កុមារ, ការថតរូបអាសអាភាស ឬត្រូវគេរំលោភបំពានលើរាងកាយជាដើម
- ធាតុផ្សំនៃការកេងប្រវ័ញ្ចផ្លូវភេទ ក៏អាចបង្ហាញតាមរយៈ**វិធីសាស្ត្រដែលប្រើប្រាស់ ដើម្បីទទួលបានរបស់របរ សេវាកម្មនានា ឬប្រាក់កាសជាដើម។** ឧទាហរណ៍ជនល្មើសអាចចូលមើល ឬប្រើរូបភាពដែលកុមារថតដោយខ្លួនឯង ហើយជនល្មើសប្រើរូបភាពនេះដើម្បីគំរាមទាប្រាក់ពីកុមារ។
- ការគំរាមឬការជំរិតផ្លូវភេទ អាចពាក់ព័ន្ធនឹង (ការគំរាមចំពោះ) ការផ្សព្វផ្សាយរូបភាពដែលកុមារថតដោយខ្លួនឯងលើបណ្តាញអ៊ីនធឺណិត ឬទៅកាន់មិត្តភក្តិរបស់កុមារ ហើយនេះ អាចបណ្តាលឱ្យមាន**ផលវិបាកលក្ខណៈអវិជ្ជមានដល់កុមារ** ដូចជាការគំរាមកំហែងដែលធ្វើឲ្យកុមាររងគ្រោះ ឬមានគ្រោះថ្នាក់បន្ថែម។

** សូមមើលតារាងព័ត៌មាន – "សិចធីង"*

## តើលោកអ្នកអាចធ្វើអ្វីខ្លះ?

- តស៊ូមតិដើម្បីឲ្យមានគោលការណ៍ច្បាប់ដែលរឹងមាំ ដែលចាត់ការជំរិត ឬគំរាមខាងផ្លូវភេទជាបទល្មើសព្រហ្មទណ្ឌ។
- តស៊ូមតិដើម្បីឲ្យមានធនធានដែលប្រសើរជាងមុន សម្រាប់មន្ត្រីអនុវត្តច្បាប់ដើម្បីដោះស្រាយបញ្ហាការជំរិត ឬគំរាមខាងផ្លូវភេទនេះ។
- តស៊ូមតិ និងសហការជាមួយក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត ដើម្បីកំណត់ចរាចរណ៍នៃ សម្ភារៈរំលោភបំពានផ្លូវភេទកុមារតាមអ៊ីនធឺណិត ដើម្បីកម្រិតឱកាសនៃអំពើជំរិត ឬគំរាមខាងផ្លូវភេទពីជនល្មើស។
- អប់រំ និងបង្កើនការយល់ដឹងក្នុងចំណោមកុមារ មាតាបិតា និងអ្នកមើលថែទាំកុមារអំពីហានិភ័យ និងផលវិបាកដែលអាចកើតមានពី សិចធីង
- ធ្វើការរាយការណ៍នៅពេលលោកអ្នកជួបប្រទះ "សិចធីង" ឬរូបភាព និងសម្ភារៈអំពីការរំលោភបំពានផ្លូវភេទលើកុមារលើបណ្តាញអ៊ីនធឺណិត។

តារាងព័ត៌មានស្តីអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារលើអ៊ីនធឺណិតនេះផលិតដោយអង្គការ ECPAT អន្តរជាតិ។
ឧបត្ថម្ភគាំទ្រសម្រាប់ការបកប្រែភាសា និងផលិតកម្ម ដែលបានផ្តល់ជូនដោយអង្គការ UNICEF។